សិទ្ធិស្ត្រីត្រូវបានការពារដោយអនុសញ្ញា ស៊ី-ដ

(លំនាំបទ ស្នេហាខ្ញុំ)

(ចង្វាក់ រ៉ាវ៉ង់) កែសម្រួលដោយក្រសួងវប្បធម៌ (១)

១-	សូមអបអរ	ស្ថារតីស្មោះសរជួយស្ត្រី	រួចផុតចាកភាពលំបាកខ្វះសិទ្ធិសេរី
	អនុសញ្ញា ស៊ី-ដ	ផ្ទៃផ្ទាល្អតបី	បានជួយឱ្យស្រីអោយចាកផុតទុក្ខ ។
២-	រស់មានន័យ	ផ្ទៃផ្ទរប្រពៃខ្ពង់ខ្ពស់មុខ	គ្មានរើសអើងលើកតំកើនទូទាំងភូមិស្រុក
	មានសមត្ថភាព	គ្មានខ្ពស់គ្មានទាបស្មើភាពទាំងងអស់	ឱ្យស្ត្រីមានមុខមាត់
		ស្មើនិងបុរស ។	
៣-	អនុសញ្ញា	ស៊ី-ដ ផ្ទៃផ្ទាចែងឥតចន្លោះ	ការរើសអើងប្រឆាំងស្ត្រីត្រូវផ្ដន្ទាទោស
	ចំណែកស្ត្រី	មានសិទ្ធិសេរីអ្វីៗទាំងអស់	ធ្វើការមានកេរ្តិ៍ឈ្មោះដូចជាបុរសដែរ ។
៤-	សិទ្ធិការងារ	សិទ្ធិបានការពាររក្សាថែ	សិទ្ធិទទួលសំរួលឧបត្ថម្ភរួមនិងប្រាក់ខែ
	សិទ្ធិធ្វើសេដ្ឋកិច្ច	នយោបាយសំរេចដូចបុរសដែរ	ស្ត្រីនិងមានសិទ្ធិលំហែមាតុភាព ។
៥-	សិទ្ធិអប់រំ	រៀនសូត្រសមរម្យមិនខ្ពស់ទាប	សិទ្ធិផ្ទៃយប់ សេវាគ្រប់គ្រង ផ្នែកសុខភាព
	សិទ្ធិគ្រប់គ្រងទ្រព្យ	សិទ្ធិដែលមានភ័ព្ធមិនចាញ់ប្រៀប	សិទ្ធិមួយទៀតសិទ្ធិអាចរៀបមង្គលការ
៦-	សូមស្វាគមន៍	សិទ្ធិដ៏ឧត្តមទាំងនេះណា	ស្ត្រីមានភ័ពភ្ជាប់ការពារដោយអនុសញ្ញា
	មានក្រុមប្រឹក្សា	ជាតិកម្ពុជាដ៏ផ្ទៃផ្ទា	ជួយថែរក្សា និងការពារសិទ្ធិស្ត្រី ។